- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៥៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបញ្ជាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៩
- យោងតាមសំណើររបស់សម្តេចប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០០

## ត្រាស់បង្គាប់

មាត្រា ១ .- តម្លើងឋានៈស្មើ អនុរដ្ឋលេខាធិការ ជូន ៖

១- លោក មាន សុខុម ជាប្រធានអគ្គាធិការ ។

២- លោកស្រី ជេត ចណ្ណលី ជាប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ។

មាត្រា ២ .- ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

***

## ព្រះរាជក្រឹត្យ នស/រកត/០១០០/០០៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ១ស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា

Downloaded from http://www.khmerlaws.com

### ត្រាស់បង្គាប់

**មាត្រា ១ .-** បង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលមានសមាសភាពដូចតទៅ ៖

១- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាប្រធាន
២- ឯកឧត្តម ឌី ណារ៉ុងរិទ្ធិ ជាអនុប្រធានប្រចាំការ មានឋានៈស្មើរដ្ឋមន្ត្រី
៣- ឯកឧត្តម លី ម៉ុរ ជាអនុប្រធាន មានឋានៈស្មើរដ្ឋលេខាធិការ
៤- ឯកឧត្តម មាន ជីវុន ជាអគ្គលេខាធិការ មានឋានៈស្មើអគ្គនាយក
និងទីប្រឹក្សាដែលមានសមាសភាព
៥- ឯកឧត្តម អ៊ឹង ឧត្តី ជាទីប្រឹក្សា មានឋានៈស្មើអនុរដ្ឋលេខាធិការ
៦- ឯកឧត្តម ថៃ ឃ្វា ជាទីប្រឹក្សា មានឋានៈស្មើអនុរដ្ឋលេខាធិការ
៧- ឯកឧត្តម បាន ចំរុង ជាទីប្រឹក្សា មានឋានៈស្មើអគ្គនាយក ។

**មាត្រា ២.-** ប្រធានប្រគល់សិទ្ធិគ្រប់គ្រងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឲ្យអនុប្រធានប្រចាំការ ។

**មាត្រា ៣.-** ការរៀបចំ និងការប្រព្រឹត្តិទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤.-** អាជ្ញាធរនេះអាចមានសមាជិកពីក្រសួងពាក់ព័ន្ធ ។

**មាត្រា ៥.-** ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/០១ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៩ និងរាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ .-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៧ .-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០០
ព្រះហស្ថលេខា
**នរោត្តម សីហនុ**

***

## II- រាជរដ្ឋាភិបាល

## ១.អនុក្រឹត្យ

### អនុក្រឹត្យលេខ ០៥ អនក្រ.តត
### ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

Downloaded from http://www.khmerlaws.com